# ការសិក្សាពីទស្សន:គ្រូ និង សិស្សថ្នាក់ទី៣ ទៅលើការអភិវឌ្ឍបំណិនទំនាក់ទំនងតាមរយៈការរៀនតាមបែបសហការ

Exploring Teacher and Student Views on Communication Skill Development via Collaborative Learning in Grade 3

*សុខ សារិកា[1], វង្ស សាវឿន[2]*
*SOK Sarika, VONG Savoeun*

## សង្ខិត្តន័យ

ការស្រាវជ្រាវនេះ សិក្សាពីទស្សន:គ្រូ និង សិស្សថ្នាក់ទី ៣ទៅលើការអភិវឌ្ឍបំណិនទំនាក់ទំនងតាមរយៈការរៀនបែបសហការនៅកម្រិតបឋមសិក្សានៅសាលាបឋមសិក្សាមួយក្នុងរាជធានីភ្នំពេញឆ្នាំសិក្សា ២០២៤-២០២៥។តាមរយៈការសង្កេតនិងសម្ភាសន៍លទ្ធផលបានបង្ហាញថាវិធីសាស្ត្រសហការជួយលើកកម្ពស់អន្តរកម្មរវាងសិស្សនិងសិស្សបង្កើនការចូលរួមសកម្មក្នុងសកម្មភាពក្រុមនិងអភិវឌ្ឍទំនួលខុសត្រូវរួម។ សិស្សបានបង្ហាញជំនាញទំនាក់ទំនងកាន់តែប្រសើរដូចជាការស្តាប់យ៉ាងសកម្មការបញ្ចេញមតិប្រកបដោយទំនុកចិត្ត និង ការឆ្លើយតបប្រកបដោយស្ថាបនា។ លើសពីនេះ វិធីសាស្ត្រនេះបានជួយកាត់បន្ថយភាពអៀនខ្មាស បង្កើនទំនុកចិត្ត និង បណ្តុះឥរិយាបទ វិជ្ជមានដូចជាការចែករំលែកគំនិតការគាំទ្រគ្នាទៅវិញទៅមក និងការដោះស្រាយជម្លោះ ។ ការស្រាវជ្រាវបានរកឃើញថា បរិយាកាសសិក្សាដែលសុវត្ថិភាព និងរីករាយបានជួយជំរុញភាពជោគជ័យទាំងផ្នែកសិក្សា និង សង្គម ។ ការសិក្សានេះ ផ្តល់អនុសាសន៍ចំពោះ អ្នកស្រាវជ្រាវជំនាន់ក្រោយគួរស្រាវជ្រាវបន្ថែមលើបញ្ហាប្រឈមនៃការអនុវត្តវិធីសាស្ត្រសហការដូចជាការគ្រប់គ្រងពេលវេលាការចែកចាយភារកិច្ចឱ្យស្មើភាព និង ការដោះស្រាយអាកប្បកិរិយាអវិជ្ជមានរបស់សិស្ស។ការស្វែងយល់ពីវិធីដោះស្រាយបញ្ហាទាំងនេះនឹងជួយធ្វើឱ្យវិធីសាស្ត្រនេះមានប្រសិទ្ធភាពកាន់តែខ្ពស់។

**ពាក្យគន្លឹះ:** *ទស្សន:គ្រូនិងសិស្ស សិស្សថ្នាក់ទី៣ បំណិនទំនាក់ទំនាក់ រៀនបែបបសហការ*

១. គរុនិស្សិត ១២+៤ ជំនាន់ទី៣ (២០២៤-២០២៥) ឯកទេសបង្រៀនកម្រិតបឋមសិក្សា
២. គ្រូឧទ្ទេសដឹកនាំ

## ABSTRACT

This research examines the perspectives of teachers and third-gradestudents on the development of communication skills through collaborative learning at a primary school in Phnom Penh during the 2024-2025 academic year. Through observations and interviews, the results indicate that collaborative methods enhance student interactions, increase active participation in group activities, and foster shared responsibility. Students demonstrated improved communication skills, such as active listening, confident expression of opinions, and constructive responses. Furthermore, this approach helped reduce shyness, boost self-confidence, and cultivate positive behaviors, including sharing ideas, mutual support, and conflict resolution. The study found that a safe and enjoyable learning environment promotes both academic and social success. The research recommends that future studies explore challenges in implementing collaborative methods, such as time management, equitable task distribution, and addressing negative student behaviors. Understanding solutions to these challenges will enhance the effectiveness of this approach.



**Key words:** *Teacher and Student Views, Grade 3, Communication Skill, Collaborative Learning*


## ១. សេចក្តីផ្តើម

នៅប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការកែលម្អគុណភាពអប់រំ ជាពិសេសនៅកម្រិតបឋមសិក្សា។ក្រសួងបានអនុវត្តគោលនយោបាយដើម្បីទាក់ទាញបុគ្គលដែលមានសមត្ថភាពឱ្យចូលបម្រើការងារជាគ្រូបង្រៀន ។ ឧទាហរណ៍បេក្ខជនដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្រសួងលើកទឹកចិត្តឱ្យប្រឡងចូលវគ្គបណ្តុះបណ្តាល គ្រូបង្រៀន (១២ + ២) និង (១២+៤) ។ បន្ថែមពីនេះ ក្រសួងបានចេញផ្សាយ "ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជា "២០៣០" នៅឆ្នាំ២០២១ ដើម្បីកំណត់ទិសដៅយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍអប់រំដោយផ្តោតលើការបណ្តុះបំណិនសតវត្សទី២១និងការប្រើបច្ចេកវិទ្យាក្នុងការសិក្សា។យោងតាមឯកសាររបស់ក្រសួងអប់រំយុវជននិងកីឡាការបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីប្រើប្រាស់វិធីសាស្ត្របង្រៀនបែបសកម្មដូចជា ការរៀនបែបសហការត្រូវបានជំរុញយ៉ាងសកម្ម ដើម្បីលើកកម្ពស់ជំនាញសតវត្សទី ២១ ដែលរួមមានទាំងជំនាញទំនាក់ទំនង។ កម្មវិធី "សៅប្រឹក្សាគរុកោសល្យ" ដែលចាប់ផ្តើមនៅឆ្នាំ២០២៣ បានផ្តោតលើការពង្រឹងសមត្ថភាពគ្រូនៅថ្នាក់អនុវិទ្យាល័យនិង វិទ្យាល័យប៉ុន្តែក៏មានផលប៉ះពាល់ដល់កម្រិតបឋមសិក្សាផងដែរ ។ កម្មវិធីនេះបានបញ្ជាក់ថាការប្រើប្រាស់កិច្ចការក្រុមនិងសកម្មភាពសហការអាចជួយសិស្សឱ្យអភិវឌ្ឍជំនាញទំនាក់ទំនងបានល្អប្រសើ។ទោះជាយ៉ាងណាការសិក្សាជាក់លាក់ទៅលើទស្សនៈរបស់គ្រូនិងសិស្សថ្នាក់ទី៣នៅកម្ពុជាលើការរៀនបែបសហការនៅមានកម្រិត។ការស្រាវជ្រាវមួយចំនួនបានបង្ហាញថាគ្រូបង្រៀនជួបបញ្ហាប្រឈមដូចជា ការខ្វះធនធាន និង ការបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់អនុវត្តវិធីសាស្ត្រនេះ។ ទស្សនៈរបស់សិស្សវិញ ត្រូវបានរកឃើញថាពួកគេរីករាយនឹងការធ្វើការងារជាក្រុមប៉ុន្តែជួនកាលមាន

ការលំបាកក្នុងការចែករំលែកគំនិតដោយសារភាពខ្មាសអៀន ឬខ្វះជំនាញទំនាក់ទំនង។( ក្រសួងអប់រំ យុវជន និង កីឡា [Ministry of Education Youth, and Sport] ,2021) ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ប្រធានបទខាងលើនេះ ត្រូវបានចាត់ចូលជាប្រធានបទស្រាវជ្រាវមួយដែលអ្នកស្រាវជ្រាវត្រូវចុះទៅអនុវត្តនិងប្រមូលទិន្នន័យត្រឡប់មកវិញតាមរយៈកម្រងសំណួរសម្រាប់ធ្វើការសម្ភាសន៍ទៅលើសិស្សនិងគ្រូ ដោយយើងនឹងត្រូវកត់ត្រានូវចម្លើយជាប្រភេទអត្ថបទ (transcript) ដោយសម្រង់នូវពាក្យសម្តីនិងធ្វើការវិភាគដោយដៃឱ្យបានល្អិតល្អន់ និង បង្ហាញលទ្ធផលជាពាក្យពេចន៍សម្តីជាអក្សរ ។ ដូចនេះយើងអាចទាញបញ្ជាក់បានថាប្រធានបទដែលយើងលើកមកស្រាវជ្រាវនេះជាប្រភេទនៃការស្រាវជ្រាវតាមបែបគុណវិស័យ ។ ការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យពឹងផ្អែកលើការសង្កេតថ្នាក់រៀន និងការសម្ភាសន៍ទូទៅទាក់ទង នឹងប្រធានបទខាងលើដែលអ្នកស្រាវជ្រាវអោចជ្រើសរើសនូវអ្នកដែល នឹងចូលរួមសម្ភាសន៍ដោយផ្ទាល់ដោយខ្លួនរបស់គេ និងធ្វើឱ្យអ្នកស្រាវជ្រាវកាន់តែយល់ច្បាស់ពីបញ្ហាស្រាវជ្រាវរបស់ពួកគេ។សំណួរដែលអ្នកស្រាវជ្រាវ នឹងលើកយកមកសម្ភាសន៍ជាប្រភេទសំណួរបើកដែលជួយដល់អ្នកដែល នឹង ត្រូវបានសម្ភាសន៍ងាយស្រួលក្នុងការផ្តល់ចម្លើយពិតជាច្រើនរបស់ពួកគេ។ សំណួរបើកដែលអនុញ្ញាតឱ្យអ្នកដែល នឹង ត្រូវបានគេសម្ភាសន៍បង្ហាញពីបទពិសោធន៍ការយល់ឃើញរបស់ពួកគេដោយផ្ទាល់ដោយ នឹង មិនត្រូវបានបដិសេដទៅលើកសំណួរសម្ភាសន៍។

### ២.១ ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺជាការប្រមូលព័ត៌មានទាំងឡាយ ដើម្បីយកមកធ្វើការវិភាគ។មួយវិញទៀតដើម្បីធ្វើការឆ្លើយតបនឹងគោលបំណងស្រាវជ្រាវ ស្វែងយល់អំពីទស្សនៈគ្រូ និង សិស្សថ្នាក់ទី ៣ ទៅលើការអភិវឌ្ឍបំណិនទំនាក់ទំនងតាមរយៈ ការរៀនតាមបែបសហការ ដែលអ្នកស្រាវជ្រាវ ធ្វើការប្រមូលទិន្នន័យតាមរយៈការសម្ភាសន៍តាមបែបពាក់កណ្តាលរចនាសម្ព័ន្ធ (Semi-Structuredinterview) ដោយប្រើប្រាស់ឧបករណ៍ជាទម្រង់កម្រងសំណួរសម្ភាសន៍សិស្សដោយរៀបចំទៅតាមលំដាប់លំដោយនៃសំណួរនីមួយៗជាក់លាក់ ដែលមានទាំងសម្ភាសន៍បុគ្គល។ ឧបករណ៍ទាំងនេះត្រូវបានប្រើប្រាស់ ដើម្បីធានាបាននូវភាពច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។

### ២.២ ឧបករណ៍ស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវ បែបគុណវិស័យ ឧបករណ៍ស្រាវជ្រាវមាន សារៈសំខាន់ណាស់សម្រាប់ការប្រមូល និងវិភាគទិន្នន័យប្រកបដោយភាពជឿជាក់ ។ ឧបករណ៍សំខាន់ដែលប្រើប្រាស់ក្នុង ការស្រាវជ្រាវនេះគឺទម្រង់សំណួរសម្ភាសន៍បែបពាក់កណ្តាលរចនាសម្ព័ន្ធ។ ទម្រង់សំណួរនេះ ត្រូវបានរៀបចំដោយអ្នកស្រាវជ្រាវដែលផ្អែកលើឯកសារពាក់ព័ន្ធ និង បានពិនិត្យសម្របសម្រួលពីគ្រូឧទ្ទេសដឹកនាំដើម្បីធានាបាននូវភាពច្បាស់លាស់ និងភាពជឿជាក់សម្រាប់ការរចនាសំណួរសម្ភាសន៍បែបគុណវិស័យ។ សំណួរទាំងនេះត្រូវបានកែសម្រួលឱ្យសមស្របនឹងបរិបទនៃសាលាបឋមសិក្សានៅកម្ពុជា និងកម្រិតនៃការយល់ដឹងរបស់សិស្សថ្នាក់ទី៣ ។ ដើម្បីធានាភាពសមស្រប ទម្រង់សំណួរត្រូវបានរៀបចំជាលំដាប់មានចំនួន ៥ សំណួរ ដោយចាប់ផ្តើម ពីសំណួរទូទៅទៅរកសំណួរជាក់លាក់ទាក់ទងនឹង ការងារក្រុម។ មុនពេលប្រើប្រាស់សំណួរទាំងនេះ អ្នកស្រាវ

ជ្រាវត្រូវបានសាកល្បងជាមួយសិស្សចំនួន ៣នាក់ (ដែលមិនមែនជាសកលគំរូ) ដើម្បីធានាថាសំណួរមានភាពច្បាស់លាស់ងាយស្រួលយល់ និង សមស្របនឹងអាយុនិងកម្រិតភាសារបស់សិស្ស។ ការសាកល្បងនេះបានជួយកែសម្រួលភាសានៃសំណួរឱ្យសាមញ្ញជាងមុន និងបញ្ចៀសភាពស្មុគស្មាញដែលធ្វើឱ្យសិស្សពិបាកយល់ពីសំណួរ។ កម្រងសំនួរសម្ភាសន៍ពិតជាមានភាពជឿជាក់បានដោយអ្នកស្រាវជ្រាវបានបង្កើតសំនួរស្របទៅតាមខ្លឹមសារនៃប្រធានបទដើម្បីឆ្លើយតបទៅនឹងសំនួរស្រាវជ្រាវបន្ថែមពីនេះ អ្នកស្រាវជ្រាវបានធ្វើការឆ្លងជាមួយគ្រូជីកនាំនិង ធ្វើការកែសម្រួលបានយ៉ាងត្រឹមត្រូវហើយបន្តពីនេះអ្នកស្រាវជ្រាវបានធ្វើការជ្រើសរើសក្នុងនោះសកលគំរូរួមមានសិស្សថ្នាក់ទី៣ ផ្សេងទាន់ចំនួន ១ថ្នាក់ ដោយសិស្សសរុបមាន ៤៥នាក់ (ស្រី ២០នាក់ និង ប្រុស ២៥នាក់)។ អ្នកស្រាវជ្រាវបានប្រើបច្ចេកទេសជ្រើសរើសសំណាកតាមគោលបំណងដើម្បីធានាថាសិស្សដែលជ្រើសរើសមានលក្ខណៈសមស្របនឹងគោលបំណងនៃការស្រាវជ្រាវ។ក្នុងចំណោមសិស្សទាំងនេះអ្នកស្រាវជ្រាវបានជ្រើសរើសសិស្សចំនួន ៣នាក់ (ស្រី ៣នាក់)សម្រាប់ការសាកល្បងសម្ភាសន៍សិស្សបុគ្គលដើម្បីធ្វើការវាស់ស្ទង់ទៅលើកសំនួរសម្ភាសន៍ និង ភាពជឿជាក់របស់សំនួតសម្ភាសន៍។ ការសម្ភាសន៍បុគ្គលត្រូវបានធ្វើឡើងជាមួយសិស្សចំនួន ៥នាក់ ដោយម្នាក់ៗចំណាយពេល ៤-៧ នាទី។ ការសម្ភាសន៍ទាំងនេះ ត្រូវបានថតសំឡេងដោយមាន ការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី សិស្ស និងអាណាព្យាបាលដើម្បីធានាក្រមសីលធម៌នៃការស្រាវជ្រាវ ។ចំណែកឯសម្ភាសន៍ជាគ្រូទទួលបន្ទុកថ្នាក់ទី៣ ត្រូវបានធ្វើឡើងចំនួន ៣ នាក់(ស្រី ៣ នាក់ ) ស្វែងយល់អំពីទស្សនៈគ្រូ និង សិស្សថ្នាក់ទី ៣ទៅលើការអភិវឌ្ឍបំណិនទំនាក់ទំនងតាមរយៈការរៀនតាមបែបសហការ ។ ការសម្ភាសន៍គ្រូនីមួយៗ មានរយៈពេល ៥-១០ នាទី និង ត្រូវបានថតសំឡេងដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី សិស្ស និងអាណាព្យាបាលនីមួយៗ។

## ២.៣ ដំណើរការប្រមូលទិន្នន័យ

ដំណើរការប្រមូលទិន្នន័យ នៅក្នុងជំពូកទី៣នៃការស្រាវជ្រាវនេះនឹងពិពណ៌នាអំពីជំហាននីមួយៗជាក់លាក់ដែលបានអនុវត្ត ដើម្បីប្រមូលទិន្នន័យបែបគុណវិស័យ (Qualitative Data) ដែលបានផ្តោតទៅលើការសម្ភាសន៍សិស្ស។ ខាងក្រោមនេះជាការពន្យល់លម្អិតបន្ថែមអំពីផ្នែកនីមួយៗនៃដំណើរការប្រមូលទិន្នន័យ៖

### ១. ការរៀបចំ

ផ្នែកនេះពន្យល់ពីជំហានដំបូងដែលអ្នកស្រាវជ្រាវបានធ្វើមុននឹងចាប់ផ្តើមប្រមូលទិន្នន័យ។ វាជាដំណាក់កាលសំខាន់ ដើម្បីធានាថា ការស្រាវជ្រាវត្រូវបានអនុវត្តប្រកបដោយ ក្រមសីលធម៌ និងមានឧបករណ៍សមស្រប។ អ្នកស្រាវជ្រាវ បានស្នើសុំការអនុញ្ញាតពីគណៈគ្រប់គ្រងនៃ សាលាបឋមសិក្សាក្នុងរាជធានីភ្នំពេញ និងឪពុកម្តាយ ឬអាណាព្យាបាលសិស្ស ដើម្បីធ្វើការសម្ភាសន៍ប្រមូលទិន្នន័យ។ នេះជាការអនុវត្តស្តង់ដារនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ ដើម្បីគោរពសិទ្ធិនិងឯកជនភាពរបស់អ្នកចូលរួម។ ការស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសាលា និង ឪពុកម្តាយ ឬអាណាព្យាបាលសិស្សបានជួយបញ្ជាក់ថាអ្នកស្រាវជ្រាវ បានធ្វើតាមក្រមសីលធម៌ និង អនុញ្ញាតឱ្យចូលទៅធ្វើការស្រាវជ្រាវនៅក្នុងសាលារៀនដោយស្របច្បាប់។ ជាពិសេស ការស្នើសុំការអនុញ្ញាតជានាថា អ្នកចូលរួមមានការយល់ព្រមស្ម័គ្រចិត្ត និងមិនមានសម្ពាធក្នុងការចូលរួម។

**២. ការអនុវត្ត**

ផ្នែកនេះពន្យល់ពីរបៀបដែលអ្នកស្រាវជ្រាវបានប្រមូលទិន្នន័យជាក់ស្តែងនៅក្នុងថ្នាក់រៀន និងការសម្ភាសន៍សិស្ស។ ការសម្ភាសន៍បុគ្គល និង ក្រុមត្រូវបានធ្វើឡើងនៅក្រៅម៉ោងរៀន និង នៅក្នុងបន្ទប់ស្ងប់ស្ងាត់ដើម្បីធានាថាសិស្សមានអារម្មណ៍សុវត្ថិភាព និងអាចឆ្លើយសំណួរដោយមិនមានសម្ពាធ។ របៀបជ្រើសរើសធ្វើការសម្ភាសន៍នៅក្រៅម៉ោងរៀនជួយជៀសវាងការរំខានដល់កម្មវិធីសិក្សា និងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាជាមួយអ្នកចូលរួមសម្ភាសន៍។ មួយវិញទៀតបរិយាកាសស្ងប់ស្ងាត់ជួយបង្កើនគុណភាពនៃការសម្ភាសន៍ព្រោះសិស្សអាចផ្តោតអារម្មណ៍និងមានទំនុកចិត្តក្នុងការចែករំលែកគំនិតរបស់ពួកគេដោយផ្ទាល់។ការសម្ភាសន៍ធ្វើនៅក្រៅម៉ោងសិក្សាក៏បានបង្ហាញពីការគោរពចំពោះពេលវេលាដ៏មានតម្លៃរបស់គ្រូបង្រៀន និងសិស្សផងដែរ។

**៣. ការកត់ត្រា**

ផ្នែកនេះពន្យល់ពីរបៀបដែលអ្នកស្រាវជ្រាវបានកត់ត្រា និងរៀបចំទិន្នន័យបន្ទាប់ពីការសម្ភាសន៍។ ការកត់ត្រាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវបានជួយធានាថាទិន្នន័យមានភាពត្រឹមត្រូវ និង ងាយស្រួលក្នុងការយកទៅវិភាគ។ ទិន្នន័យបានពីការសម្ភាសន៍ត្រូវបានថតសំឡេង (ដោយមានការអនុញ្ញាត)និង បម្លែងជាអក្សរ (Transcribed) ដើម្បីធានាថាគ្រប់ពាក្យរបស់អ្នកចូលរួមសម្ភាសន៍ត្រូវបានកត់ត្រាយ៉ាងលម្អិត និង ត្រឹមត្រូវ។ ការបម្លែងជាអក្សរជួយសម្រួលដល់ការវិភាគទិន្នន័យព្រោះអ្នកស្រាវជ្រាវអាចអាននិងកំណត់កូដ (Coding) ពីចម្លើយរបស់សិស្ស។ យ៉ាងណាមិញ ថតសំឡេងកាត់បន្ថយកំហុសក្នុងការកត់ត្រានិង ជួយឱ្យអ្នកស្រាវជ្រាវបានផ្តោតលើការសម្ភាសន៍ជាជាងការសរសេរ។

## ២.៤ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យនៃ ការស្រាវជ្រាវលើប្រធានបទ ស្វែងយល់អំពីទស្សនៈគ្រូ និង សិស្សថ្នាក់ទី ៣ ទៅលើការអភិវឌ្ឍបំណិនទំនាក់ទំនងតាមរយៈ ការរៀនតាមបែបសហការ។ ក្នុងការសិក្សារបស់សិស្សនៅកម្រិតបឋមសិក្សាថ្នាក់ទី ៣ មុខវិជ្ជាសិក្សាសង្គម ដើម្បីឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាពសម្រាប់ទិន្នន័យដែលទទួលបានតាមរយៈកាសង្កេត និង ការសម្ភាសន៍យើងនឹងធ្វើ ការវិភាគដោយស្រង់ទិន្នន័យទាំងនោះដាក់តាមផ្នែកនីមួយៗ និង ទៅតាមលក្ខណៈរបស់វាហើយធ្វើ ការញែកទិន្នន័យថាតើទិន្នន័យឬព័ត៌មានណាខ្លះដែលវាឆ្លើយតបនឹងគោលបំណងក៏ដូចជាប្រធានបទស្រាវជ្រាវ។ រាល់ទិន្នន័យព័ត៌មានដែលឆ្លើយតបនឹងប្រធានបទយើងនឹងធ្វើចំណែកថ្នាក់ឱ្យមានភាពសមស្របសម្រាប់ការសរសេរពន្យល់បកស្រាយលទ្ធផលដោយមានហេតុផល ឬអំណះអំណាងត្រឹមត្រូវដើម្បីឈានទៅរក ការទាញសេចក្តីសន្និដ្ឋានជារួម និង ប្រើប្រាស់ ឬ អនុវត្តបាននូវការវាយតម្លៃទាំងនោះក្នុងការបង្រៀន និងរៀនរបស់គ្រូ និងសិស្សឱ្យកាន់តែមានប្រសិទ្ធភាព។

# ៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

## ៤.១ លទ្ធផលស្រាវជ្រាវ

### ៤.១.១ អន្តរកម្មរវាងសិស្សនិងសិស្ស

អន្តរកម្មរវាងសិស្ស និង សិស្ស គឺជាដំណើរការដ៏សំខាន់សម្រាប់ជោគជ័យទាំងក្នុងជីវិតផ្ទាល់ខ្លួននិងវិជ្ជាជីវៈ។ ជំនាញនេះអាចត្រូវបានកសាង និង កែលម្អតាមរយៈការអនុវត្តជាប្រចាំដោយផ្តោតលើធាតុផ្សំ

សំខាន់ៗចំនួនបីៈ ការបញ្ចេញមតិ ការស្តាប់យ៉ាងសកម្ម និង ការឆ្លើយតបប្រកបដោយស្ថាបនា។ ការបញ្ចេញមតិ គឺជាសមត្ថភាពនៃការបង្ហាញគំនិត អារម្មណ៍ ឬព័ត៌មានឱ្យច្បាស់លាស់ និង សមស្រប។ ដើម្បីអភិវឌ្ឍជំនាញនេះ គួរជ្រើសរើសពាក្យសម្តីឱ្យត្រូវនឹងបរិបទ និង ទស្សនិកជនព្រមទាំងយកចិត្តទុកដាក់លើទឹកមុខ កាយវិការ និងសំឡេង។ ឧទាហរណ៍ ការប្រើភាសាវិជ្ជមាន និង  ជៀសវាងពាក្យសម្តីអវិជ្ជមាន អាចជួយបង្កើតបរិយាកាសទំនាក់ទំនងដ៏រីករាយ។ ការអនុវត្តការនិយាយជាសាធារណៈ ឬការសរសេរគំនិតច្បាស់លាស់ក៏ជួយពង្រឹងសមត្ថភាពនេះដែរ។ [ … ] ក្រោយពេលរៀនបែបសហការកូនបានអភិវឌ្ឍខ្លួនឯងសរសេរឱ្យលឿន និងច្បាស់ឱ្យគ្រូមើលឃើញនិងមានភាពភ្លាហាន។ [...] (ST1, IDI) ការស្តាប់យ៉ាងសកម្ម គឺជាការផ្តល់ការយកចិត្តទុកដាក់ពេញលេញចំពោះអ្នកនិយាយ ដោយមិនរំខាន និង បង្ហាញការយល់ចិត្ត។ ជំនាញនេះទាមទារការផ្តោតលើខ្លឹមសារដែលអ្នកដទៃកំពុងនិយាយជាជាងគិតពីអ្វីដែលនឹងឆ្លើយតប។ ឧទាហរណ៍ ការងក់ក្បាល  និង ការសួរសំណួរបញ្ជាក់ដូចជា «ខ្ញុំយល់ថា អ្នកមានន័យថា...» បង្ហាញថាអ្នកពិតជាស្តាប់ដោយយកចិត្តទុកដាក់។ ការអនុវត្តការស្តាប់សកម្មជួយកាត់បន្ថយការយល់ច្រឡំ និង បង្កើនទំនុកចិត្តក្នុងទំនាក់ទំនង។ [ … ] កូនបានជួយដល់ក្រុមរបស់កូនមានដូចជាជួយពិភាក្សាក្រុម និង ជួយពន្យល់គ្នា។ [...] (ST3, IDI) ការឆ្លើយតបប្រកបដោយស្ថាបនា គឺជាការផ្តល់ចម្លើយ ឬមតិយោបល់ដែលជួយជំរុញការសន្ទនា និង ដោះស្រាយបញ្ហាដោយវិជ្ជមាន ។ ជំនាញនេះទាមទារការគិតមុននិយាយ និង  ការបង្ហាញមតិដែលសមរម្យ ទោះបីជាមានភាពខ្លីចឆ្នាស់ក៏ដោយ។  ឧទាហរណ៍ ជំនួសឱ្យការនិយាយថា «គំនិតនេះមិនអាចទៅរួចទេ» អ្នកអាចនិយាយថា « ខ្ញុំឃើញគំនិតនេះគួរឱ្យចាប់អារម្មណ៍ ប៉ុន្តែប្រហែលជាយើងអាចសាកល្បងវិធីនេះបន្តែម...»។ ការផ្តល់មតិយោបល់ប្រកបដោយស្ថាបនាជួយរក្សាទំនាក់ទំនងល្អ និង លើកទឹកចិត្តឱ្យមានការសហការគ្នា។ [ … ] កូនបានជួយដល់ក្រុមរបស់កូនមានដូចជាឡើងបទបង្ហាញនិងពិភាក្សាក្រុមនិងសរសេរ។ [...] (ST5, IDI)  សរុបមកការអភិវឌ្ឍជំនាញទំនាក់ទំនងទាមទារការអនុវត្តជាប់លាប់នៃការបញ្ចេញមតិឱ្យច្បាស់លាស់ ការស្តាប់ដោយសកម្ម និង ការឆ្លើយតបប្រកបដោយស្ថាបនា។ តាមរយៈការផ្តោតលើធាតុផ្សំទាំងនេះ  បុគ្គលអាចបង្កើនសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និង បង្កើតទំនាក់ទំនងដ៏រឹងមាំជាមួយអ្នកដទៃ។ [ … ] ក្រោយពេលរៀនបែបសហការកូនបានអភិវឌ្ឍខ្លួនឯងសរសេរឱ្យលឿន និង ច្បាស់ឱ្យគ្រូមើលឃើញនិងមានភាពភ្លាហាន។ [...]  ( ST2, IDI)

## ៤.១.២ បង្កើតការចូលរួមសិក្សា

បង្កើតការចូលរួមសិក្សាគឺជាដំណើរការដ៏សំខាន់សម្រាប់រក្សាសុខភាពផ្លូវចិត្ត និង ផ្លូវកាយដែលអាចសម្រេចបានដោយការបញ្ចូល អារម្មណ៍សប្បាយចិត្ត និង សប្បាយរីករាយ ទៅក្នុងជីវិតប្រចាំថ្ងៃ និងការសិក្សា ។ ដើម្បីសម្រេចបាននេះ  គួរអនុវត្តសកម្មភាពដែលជំរុញភាពវិជ្ជមាន  ដូចជា ការធ្វើលំហាត់ប្រាណដើរលេងកម្សាន្តក្នុងធម្មជាតិ ឬចំណាយពេលជាមួយមនុស្សជាទីស្រឡាញ់។ ឧទាហរណ៍ ការស្តាប់តន្ត្រីដែលចូលចិត្ត ឬការអនុវត្តសមាធិអាចជួយបន្ធូរអារម្មណ៍ និងបង្កើតអារម្មណ៍សប្បាយរីករាយ។ ការផ្តោតលើ ការដឹងគុណ  ដូចជាការសរសេរពីរបីយ៉ាងដែល  អ្នកអរគុណជារៀងរាល់ថ្ងៃ ក៏ជួយផ្លាស់ប្តូរទស្សនៈឱ្យកាន់តែវិជ្ជមាន និង កាត់បន្ថយភាពតានតឹងបាន។ ការបណ្តុះទម្លាប់ទាំងនេះជាប្រចាំនឹងជួយឱ្យអ្នកមានអារម្មណ៍សប្បាយចិត្ត និង

សម្រាកបានល្អ ទោះបីជាមានសម្ពាធក្នុងជីវិតក៏ដោយ។ [...] ការរៀនបែបសហការកូនមានអារម្មណ៍សប្បាយចិត្ត ។[...] (ST2&ST5, IDI)

### ៤.១.៣ ចំណុចខ្សោយត្រូវការងារក្រុម

ចំណុចខ្សោយត្រូវការងារក្រុម គឺ ជាកត្តាសំខាន់សម្រាប់ធានាប្រសិទ្ធភាព និង ជោគជ័យក្នុងការសម្រេចគោលដៅរួម ដែលទាមទារការចាត់តាំងតួនាទីឱ្យច្បាស់លាស់។ ការចាត់តាំងតួនាទីមានន័យថា កំណត់ភារកិច្ចជាក់លាក់សម្រាប់សមាជិកម្នាក់ៗដោយផ្អែកលើជំនាញ និង សមត្ថភាពរបស់ពួកគេ ដើម្បីជៀសវាងការកាន់ច្រឡំ និងបង្កើនផលិតភាព។ ឧទាហរណ៍ ក្នុងក្រុមគម្រោងអ្នកខ្លះអាចទទួលខុសត្រូវលើការស្រាវជ្រាវ ខណៈអ្នកផ្សេងទៀតគ្រប់គ្រង ការប្រាស្រ័យទាក់ទង ឬការធ្វើបទបង្ហាញ។ ការទទួលខុសត្រូវរួមគ្នាក៏រួមបញ្ចូលការគោរពពេលវេលា ការសហការដោយភាពស្មោះត្រង់ និង ការគាំទ្រគ្នាទៅវិញទៅមក។ តាមរយៈការចាត់តាំងតួនាទីឱ្យសមស្រប និង ការប្តេជ្ញាចិត្តរួម ក្រុមអាចដំណើរការបានរលូន និងសម្រេចបានលទ្ធផលដ៏ល្អប្រសើរ។ [...] ការរៀនបែបសហការកូនមានភារកិច្ចជា អ្នកឡើងបទបង្ហាញ អ្នកកំណត់ពេលវេលា ។ [...] (ST4&ST5, IDI)

### ៤.១.៤ ចំណុចខ្សោយរបស់សិស្ស

ចំណុចខ្សោយរបស់សិស្ស គឺជាកត្តាដ៏សំខាន់សម្រាប់ជំរុញភាពជោគជ័យក្នុងការសិក្សាដែលអាចអភិវឌ្ឍបានតាមរយៈការចូលរួមសកម្មភាពសិក្សា និង ការបញ្ចេញមតិ។ ការចូលរួមសកម្មភាពសិក្សាដូចជាការពិភាក្សាក្រុម គម្រោងស្រាវជ្រាវ ឬ ការបង្ហាញមុខវិជ្ជា ជួយឱ្យសិស្សមានឱកាសអនុវត្តជំនាញ និងទទួលបានមតិយោបល់ស្ថាបនា ដែលបង្កើនចំណុចខ្សោយលើសមត្ថភាពខ្លួន។ ការបញ្ចេញមតិដោយសេរីក្នុងថ្នាក់ ឬការសរសេរគំនិតច្បាស់លាស់ ជួយឱ្យសិស្សហ៊ានបង្ហាញខ្លួនឯង និង កាត់បន្ថយការភ័យខ្លាចក្នុងការសម្តែង។ ឧទាហរណ៍ការលើកដៃឆ្លើយសំណួរ ឬការចែករំលែកគំនិតក្នុងក្រុមតូចៗ អាចជាជំហានដំបូងដើម្បីបង្កើតភាពក្លាហាន។ តាមរយៈការអនុវត្តជាប្រចាំនៃសកម្មភាពទាំងនេះ សិស្សនឹងបង្កើនចំណុចខ្សោយ និងសមត្ថភាពក្នុងការប្រឈមនឹងបញ្ហាសិក្សាដោយភាពជឿជាក់។ [...] ក្រោយពេលរៀនបែបសហការកូនបានអភិវឌ្ឍខ្លួនឯងចេះអានខ្លាំងចេះជាងមុន និងបានបង្ហាញលទ្ធផលទៅកាន់សមាជិកក្រុម ។ [...] (ST3, IDI)

## ៤.២. លទ្ធផលការសម្ភាសន៍គ្រូ

តាមលទ្ធផលនៃការវិភាគទិន្នន័យជាបុគ្គលជាមួយតំណាងគំរូជាគ្រូប្រចាំថ្នាក់ទី៣បានបង្ហាញលទ្ធផលឆ្លើយតប និង សំណួរស្រាវជ្រាវ"តើការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបសហការបានអភិវឌ្ឍបំណិនទំនាក់ទំនងសិស្សដូចម្តេច?ដូចខាងក្រោម ៖

- អន្តរទំនាក់ទំនងរវាងសិស្សនិងសិស្ស
- របៀបរៀនតាមបែបសហការ
- ការប្រែប្រួលឥរិយាបទ

អន្តរទំនាក់ទំនងរវាងសិស្ស និង សិស្ស គឺ ជាដំណើរការសំខាន់ដើម្បីបង្កើតបរិយាកាសសិក្សាដ៏រីឆ្ងមានដែលអាចសម្រេចបានតាមរយៈ ការដោះស្រាយជម្លោះ ការងារក្រុម និង ការបង្រៀនគ្នាទៅវិញទៅមក។

ការដោះស្រាយជម្លោះដោយការស្តាប់យ៉ាងសកម្ម និងការស្វែងរកដំណោះស្រាយរួម ដូចជាការពិភាក្សាដោយសន្តិវិធី ជួយកាត់បន្ថយភាពតានតឹង និងបង្កើនការយល់ចិត្តគ្នា។ ការងារក្រុមដូចជាការធ្វើគម្រោងរួម លើកទឹកចិត្តឱ្យសិស្សចែករំលែកគំនិត និងរៀនគោរពភាពខុសគ្នា។ ការបង្រៀនគ្នាទៅវិញទៅមកដូចជាការពន្យល់មេរៀនឱ្យមិត្តរួមថ្នាក់ មិនត្រឹមតែពង្រឹងចំណេះដឹងប៉ុណ្ណោះទេថែមទាំងបង្កើនទំនុកចិត្តនិងទំនាក់ទំនងដ៏រឹងមាំ។ តាមរយៈការអនុវត្តសកម្មភាពទាំងនេះ សិស្សអាចបង្កើតទំនាក់ទំនងដ៏ស្និទ្ធស្នាលនិងសហការប្រកបដោយប្រសិទ្ធភាព។ [...] វិធីសាស្ត្របង្រៀនដើម្បីលើកកម្ពស់ទំនាក់ទំនងល្អរវាងសិស្ស និង សិស្ស គឺនៅពេលសិស្សមានជម្លោះក្នុងថ្នាក់អ្នកគ្រូតែងតែហៅសិស្សមកជំរាបសួរគ្នា និងក្នុងករណីសិស្សប្រុសត្រូវអោបគ្នាទៅវិញទៅមក អ្នកគ្រូពន្យល់សិស្សបន្ថែមថាយើងត្រូវរស់នៅជាមួយគ្នាយើងត្រូវចេះស្រលាញ់គោរពគ្នា។[...] ( T9, IDI )

របៀបរៀនបែបសហការផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សិស្ស ដោយជំរុញការគាំទ្រគ្នា ការផ្លាស់ប្តូរគំនិត និងឯករាជ្យភាពក្នុងការសិក្សា ។ រៀបចំថ្នាក់រៀនដើម្បីងាយស្រួលសម្រេចគោលបំណងនៃការរៀនបែបសហការ។ សិស្ស ត្រូវអង្គុយតាមក្រុម និង មានកន្លែងទូលាយ ។ បង្ហាញគោលបំណងជារបស់ក្រុមទាំងមូល ។ ការរំពឹងទុកនិងចេតនាទំនាក់ទំនង ។ សិស្សត្រូវយល់ថា អ្វីដែលគេប៉ុនប៉ង។ជំរុញផ្នែកកម្លាំងដែលសមស្រប សិស្សគួរតែយល់តួនាទី និង ការទទួលខុសត្រូវរបស់គេ។ ជំរុញសិស្សឱ្យចែករំលែកគំនិត សម្ភារៈ និងធនធាន។ សិស្សគួរតែមើលគ្នាទៅវិញទៅមក មិនមែនគ្រូទេ។ គ្រូគ្រាន់តែជាអ្នកជំរុញ។ ផ្តល់សម្ភារៈឱ្យបានច្រើន ដើម្បីឱ្យដំណើរការក្រុមរលូន។ជំរុញសិស្សឱ្យធ្វើការបង្ហាញគំនិតរបស់គេឱ្យបានច្បាស់។ ជំរុញឱ្យមានឥរិយាបថគាំទ្រ និងកាត់ចេញនូវចំណុចកាត់ឱ្យបានល្អ ។ ផ្តល់សញ្ញាសមរម្យ ។ ចង្អុលបង្ហាញក្រុមឱ្យច្បាស់លាស់ ប្រើសំឡេងខ្លាំង។ ឬលើកដាក់ សំឡេងជាដើម។ពិនិត្យតាមដានក្រុម។ មើលសកម្មភាពទាំងបុគ្គលផង និង ទាំងក្រុមផង។ វាយតម្លៃទាំងបុគ្គលនិងក្រុម។ផ្តល់រង្វាន់លើកទឹកចិត្តដល់ក្រុមដែលឈ្នះ បន្ទាប់ពីការវាយតម្លៃ។តាមរយៈការងារក្រុម សិស្សអាចគាំទ្រគ្នាទៅវិញទៅមកដោយចែករំលែកចំណេះដឹង និងជួយដោះស្រាយបញ្ហា ដែលជួយបង្កើនទំនុកចិត្ត និងកាត់បន្ថយភាពឯកោ។ ការផ្លាស់ប្តូរគំនិតក្នុងការពិភាក្សា ឬគម្រោងរួមជួយឱ្យសិស្សរៀនពីទស្សនៈផ្សេងៗ និងអភិវឌ្ឍជំនាញទំនាក់ទំនង។ ទន្ទឹមនឹងនេះការរៀនបែបសហការលើកទឹកចិត្តឱ្យសិស្សបង្កើតឯករាជ្យភាព ដោយរៀនទទួលខុសត្រូវលើការកិច្ចផ្ទាល់ខ្លួនរបស់ពួកគេក្នុងក្រុម ដូចជាការស្រាវជ្រាវ ឬការបង្ហាញ ។ តាមរយៈការអនុវត្តទាំងនេះ ការរៀនបែបសហការមិនត្រឹមតែជួយពង្រឹងចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងបណ្តុះជំនាញសង្គម និងភាពជឿជាក់សម្រាប់ជោគជ័យទាំងក្នុង និងក្រៅថ្នាក់រៀន។ [...] អ្នកគ្រូយល់ឃើញការរៀនបែបសហការសិស្សចេះផ្លាស់ប្តូរយោបល់ និង ចែករំលែកចំណេះដឹងគ្នាទៅវិញទៅមកចំណែកការរៀនបុគ្គលសិស្សមានភាពឯករាជម្ចាស់ការលើកខ្លួនឯងដោយមិនពឹងពាក់អ្នកណា និង ប្រឹងបង្កើតគំនិតដោយខ្លួនឯង ។[...] ( T3,IDI ) ការប្រែប្រួលឥរិយាបថគឺជាដំណើរការនៃការផ្លាស់ប្តូរអាកប្បកិរិយា ឬទម្លាប់ឱ្យកាន់តែប្រសើរឡើង ដែលអាចសម្រេចបានតាមរយៈការអភិវឌ្ឍឥរិយាបទជួយគ្នា ភាពស្និទ្ធស្នាល និងភាពក្លាហាន។ឥរិយាបទ ជួយគ្នាដូចជាការចែករំលែកធនធាន ឬការគាំទ្រមិត្តរួមថ្នាក់ក្នុងការសិក្សាជួយបង្កើតបរិយាកាសសហការនិងកាត់បន្ថយភាពតានតឹង។ ភាពស្និទ្ធស្នាល ដែលកើតចេញពីការសន្ទនាបើកចំហ និងការស្តាប់យ៉ាងយកចិត្តទុកដាក់ ជួយពង្រឹងទំនាក់ទំនង និង បង្កើនការយល់ចិត្តគ្នា។ ភាពក្លាហានដូចជាការហ៊ានបញ្ចេញមតិ ឬសាកល្បងរឿងថ្មីៗ ដូចជាការចូលរួមបទបង្ហាញ ជាសាធារណៈជួយបុគ្គលឱ្យជម្នះភាពភ័យ

ខ្លាច និងបង្កើនទំនុកចិត្ត។ តាមរយៈការអនុវត្តឥរិយាបទទាំងនេះជាប្រចាំសិស្សអាចផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនឱ្យកាន់តែវិជ្ជមាន និងសម្រេចបាននូវការរីកចម្រើនទាំងផ្នាល់ខ្លួន និងសង្គម។ [...] តាមរយៈការអនុវត្តវិធីសាស្ត្របង្រៀនបែបសហការអ្នកគ្រូសង្កេតឃើញថាសិស្សទទួលបានលទ្ធផលនៃការប្រែប្រួលឥរិយាបទកាន់តែល្អជាងមុនដោយសិស្សចេះជួយគ្នាទៅវិញទៅមកបន្ថែមពីនេះសិស្សចេះចែករំលែកគ្នាទៅវិញទៅមក។[...] ( T3,IDI )

## ៤.៣ ការពិភាក្សា

### ៤.៣.១ ការពិភាក្សាលទ្ធផលសិស្ស

ការសិក្សាស្រាវជ្រាវខាងលើកនេះបានរកឃើញថាការប្រើប្រាស់វិធីសាស្ត្រសហការជួយអភិវឌ្ឍជំនាញទំនាក់ទំនងសិស្សដូចជា( ១ )អន្តរកម្មរវាងសិស្ស និង សិស្ស ( ២ )បង្កើនការចូលរួមសិក្សា ( ៣ )ទំនួលខុសត្រូវការងារក្រុម និង ( ៤ )ទំនុកចិត្តរបស់សិស្ស។ លទ្ធផលការសិក្សាស្រាវជ្រាវនេះមានភាពដូចគ្នាទៅនឹងលទ្ធផល Mom, P. etal.( 2023 )ដែលបង្ហាញថា ការអនុវត្តវិធីសាស្ត្រសហការការ បានរកឃើញថាបានពង្រឹងជំនាញទំនាក់ទំនងតាមរយៈសកម្មភាពក្រុម និងជួយសិស្សអភិវឌ្ឍជំនាញទំនាក់ទំនងផ្នាល់មាត់ដូចជាការបញ្ចេញមតិ ការស្តាប់យ៉ាងសកម្ម និងការឆ្លើយតបប្រកបដោយស្ថាបនា ។ ទន្ទឹមនឹងនេះការស្រាវជ្រាវនេះក៏ស្របទៅតាមលទ្ធផល JICA ( 2021 ) ការអនុវត្តវិធីសាស្ត្រសហការការបានរកឃើញថា ការលើកកម្ពស់ជំនាញសង្គម និងការដោះស្រាយបញ្ហាបន្ថែមពីនេះ សិស្សអភិវឌ្ឍជំនាញសង្គម ដូចជាការចរចា ការគ្រប់គ្រងជម្លោះ និងការធ្វើការងារជាក្រុមទំនួលខុសត្រូវ។លើសពីនេះការស្រាវជ្រាវក៏នេះក៏រកឃើញលទ្ធផលដូច Johnson et al. ( 2023 ) ការអនុវត្តវិធីសាស្ត្រសហការបានរកឃើញថាវាអាចកាត់បន្ថយភាពតានតឹង និង បង្កើនការចូលរួមសិក្សា។ បន្ថែមពីនេះការស្រាវជ្រាវនេះក៏រកឃើញលទ្ធផលនៃការស្រាវជ្រាវដូច National Institute of Education ( 2023 ) ការអនុវត្តវិធីសាស្ត្រសហការបានរកឃើញថាជួយបង្កើនការចូលរួម និង ទំនុកចិត្តរបស់សិស្សហើយបរិយាកាសសហការដែលសុវត្ថិភាព និង លើកទឹកចិត្តជួយសិស្ស បង្កើនទំនុកចិត្តក្នុង ការបញ្ចេញមតិ និងចូលរួមសកម្មភាពសិក្សា ។ នេះជួយកាត់បន្ថយភាពអៀនខ្មាសនិងអភិវឌ្ឍជំនាញទំនាក់ទំនងជាសាធារណៈ។

### ៤.៣.២ ការពិភាក្សាលទ្ធផលគ្រូ

ការសិក្សាស្រាវជ្រាវខាងលើកនេះបានរកឃើញថា ការប្រើប្រាស់វិធីសាស្ត្រសហការជួយអភិវឌ្ឍជំនាញទំនាក់ទំនងសិស្សដូចជា ១ ) អន្តរទំនាក់ទំនងរវាងសិស្សនិងសិស្ស ២ ) របៀបរៀនតាមបែបសហការ និង៣ ) ការប្រែប្រួលឥរិយាបទ។ លទ្ធផលការសិក្សាស្រាវជ្រាវនេះ មានភាពដូចគ្នាទៅនឹងលទ្ធផលYusuf et al. ( 2019 ) ការអនុវត្តវិធីសាស្ត្រសហការ បានបង្ហាញថា បានបង្កើតការចូលរៀនបែបសកម្មនៅក្នុងថ្នាក់រៀនជួយបង្កើនសមត្ថភាពទំនាក់ទំនងរបស់សិស្សជាពិសេសនៅក្នុងការបញ្ចេញមតិ និង ការស្តាប់សកម្ម។ លើសពីនេះការស្រាវជ្រាវនេះក៏រកឃើញលទ្ធផលដូច Slavin ( 1996 ) បានរកឃើញថា វិធីសាស្ត្រសហការជួយឱ្យសិស្សមានការចូលរួមកាន់តែច្រើននិងបង្កើនជំនាញសង្គមជាពិសេសការស្តាប់សកម្មនិង ការបញ្ចេញមតិ។

## ៥. សេចក្តីសន្និដ្ឋាន

### ៥.១ សរុបសេចក្តី

ការសិក្សាស្រាវជ្រាវទៅលើកប្រធានបទ "ការសិក្សាពីទស្សនៈគ្រូ និង សិស្សថ្នាក់ទី ៣ ទៅលើការអភិវឌ្ឍបំណិនទំនាក់ទំនង"។ ដោយផ្អែកទៅលើលទ្ធផលដែលបានអ្នកស្រាវជ្រាវបានបង្ហាញនៅក្នុងជំពូកទី ៤ និង ការពិភាក្សា អ្នកស្រាវជ្រាវសន្និដ្ឋានបានថា៖ ការរៀនតាមបែបសហការ គឺការអនុវត្តសកម្មភាពក្រុម ដូចជា ការពិភាក្សា គម្រោងរួម និងការចែករំលែកគំនិតសិស្ស មិនត្រឹមតែអភិវឌ្ឍជំនាញទំនាក់ទំនងប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបង្កើនទំនុកចិត្ត ការចូលរួមសកម្ម និង ភាពស្និទ្ធស្នាលក្នុងចំណោមមិត្តរួមថ្នាក់។ លទ្ធផលស្រាវជ្រាវ បានបញ្ជាក់ថាវិធីសាស្ត្រសហការជួយឱ្យសិស្សអភិវឌ្ឍជំនាញស្តាប់យ៉ាងសកម្មបញ្ចេញមតិប្រកបដោយស្ថាបនា និង ដោះស្រាយបញ្ហារួមគ្នាដែលជាមូលដ្ឋានសំខាន់សម្រាប់ជោគជ័យទាំងក្នុងការសិក្សា។ លទ្ធផលពីការ សម្ភាសន៍ និង ការសង្កេតបានបញ្ជាក់ថា សិស្សដែលចូលរួមក្នុងសកម្មភាពសហការមានភាពសកម្មជាងមុន ហ៊ានបញ្ចេញមតិ និង បង្ហាញភាពក្លាហានក្នុងការចូលរួមបទបង្ហាញនៅក្នុងថ្នាក់រៀន។ ការផ្លាស់ប្តូរឥរិយាបថ ទាំងនេះបានរួមចំណែកដល់ការបង្កើនទំនុកចិត្តជាពិសេសនៅក្នុងការនិយាយ និងការស្តាប់។ លើសពីនេះគ្រូ បង្រៀនបានសង្កេតឃើញថា វិធីសាស្ត្រសហការបានធ្វើឱ្យបរិយាកាសថ្នាក់រៀនកាន់តែរីករាយ និង ជួយឱ្យ សិស្សមានចំណាប់អារម្មណ៍កាន់តែច្រើនលើមុខវិជ្ជាសិក្សាសង្គម។

### ៥.២ អនុសាសន៍

អនុសាសន៍អំពីវិធីប្រើប្រាស់ វិធីបង្រៀននិងរៀនដល់អ្នកស្រាវជ្រាវនិងគ្រូបង្រៀនបន្តវេន៖ តាមរយៈ ការស្រាវជ្រាវលើប្រធានបទ"ការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបសហការបានអភិវឌ្ឍបំណិន ទំនាក់ទំនងសិស្ស" គឺ លោកគ្រូ អ្នកគ្រូអាចសាកល្បងក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែប សហការ លើមុខវិជ្ជាសិក្សាសង្គម នៅបឋមសិក្សាបានដើម្បីធ្វើឱ្យបរិយាកាសថ្នាក់រៀនប្រកបដោយភាពរីករាយ។ គ្រូបង្រៀនគ្រប់រូបត្រូវប្រើប្រាស់នូវវិធីសាស្ត្រថ្មីៗ និង ចេះកែច្នៃនៅអ្វីថ្មីៗល្អៗបន្ថែមទៀតយកមកប្រើ ប្រាស់ក្នុងការបង្រៀន ដើម្បីឱ្យការបង្រៀននិងរៀនប្រកបដោយប្រសិទ្ធភាពនិងចីរភាព ដើម្បីអភិវឌ្ឍន៍វិស័យ អប់រំនៅប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនឡើង ។

អនុសាសន៍ចំពោះអ្នកស្រាវជ្រាវបន្តវេន អ្នកស្រាវជ្រាវគួរប្រើទម្រង់សង្កេតសិស្សក្នុងអំឡុងពេលរៀន តាមបែបសហការ ដើម្បីស្វែងយល់ពីបំណិតទំនាក់ទំនងរបស់សិស្ស ។ អ្នកស្រាវជ្រាវគួរស៊ើបអង្កេតពី របៀបដែល វិធីសាស្ត្រសហការអាចកាត់បន្ថយភាពប្រកាន់ពូជសាសន៍ឬអាកប្បកិរិយាអវិជ្ជមាននៅក្នុងថ្នាក់រៀនចម្រុះការ សិក្សាអាចផ្តោតលើការបង្កើតបរិយាកាសសហការដែលលើកកម្ពស់ការយល់ចិត្តនិងការគោរពគ្នាទៅវិញទៅមក។

## ៦. ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា.(២០២១). *ក្របខ័ណ្ឌកម្មវិធីសិក្សាសម្រាប់អប់រំបឋមសិក្សា*. ក្រសួងអប់រំ យុវជន និងកីឡា ភ្នំពេញ ។

ឃិន វណ្ណី. (2021 ). *វិធីសាស្ត្របង្រៀន* (បោះពុម្ពលើកទី៤). ភ្នំពេញ គ្រឹះស្ថានបោះពុម្ពឯកសារខ្មែរ

AhaSlides. (2022). 15 innovative teaching methods. *AhaSlides*. Retrieved July 8, 2025, from https://ahaslides.com

AhaSlides. (2022). 15 innovative teaching methods. *AhaSlides*. Retrieved July 9, 2025, from https://ahaslides.com

Afari, E. (2012). The effects of psychosocial learning environment on students' attitudes towards mathematics [Preprint]. *OSF Preprints*. https://doi.org/10.31219/osf.io/9km3u

Argyle, M. (1972). *The social psychology of everyday life*. Routledge.

Bruffee, K. A. (1993). *Collaborative learning: Higher education, interdependence, and the authority of knowledge*. Johns Hopkins University Press.

Bandura, A. (1977). *Social learning theory*. Prentice Hall.

Bonwell, C. C., & Eison, J. A. (1991). *Active learning: Creating excitement in the classroom* (ASHE-ERIC Higher Education Report No. 1). The George Washington University, School of Education and Human Development.

Bonwell, C. C., & Eison, J. A. (1991). Active learning: Creating excitement in the classroom (ASHE-ERIC Higher Education Report No. 1). The George Washington University, School of Education and Human Development.

Bruner, J. S. (1961). *The act of discovery*. Harvard University Press.

Dewey, J. (1916). *Democracy and education*. Macmillan.

Habermas, J. (1984). *The theory of communicative action: Reason and the rationalization of society*. Beacon Press.

Indeed Editorial Team. (2023). Communication skills: Definitions and examples. Indeed. Retrieved July 9, 2025, from https://in.indeed.com/career-advice/resumes-cover-letters/communication-skills

Johnson, D. W., & Johnson, R. T. (1999). *Learning together and alone: Cooperative, competitive, and individualistic learning* (5th ed.). Allyn & Bacon.

Johnson, D. W., & Johnson, R. T. (1999a). *Learning together and alone: Cooperative, competitive, and individualistic learning (5th ed.)*. Allyn & Bacon.

Johnson, D. W., & Johnson, R. T. (1999b). Making cooperative learning work. *Theory Into Practice*, 38(2), 67–73. https://doi.org/10.1080/00405849909543834

Johnson, D. W., & Johnson, R. T. (1998). *Learning together and alone: Cooperative, competitive, and individualistic learning (5th ed.)*. Allyn & Bacon. https://doi.org/10.xxxx/xxxxxx (Note: Replace with actual DOI if available)

Nugraha, B. A. (2013). Group investigation. Scribd. Retrieved July 9, 2025, from https://www.scribd.com/doc/194341823/Group-Investigation

Optimist Minds. (2023). 6 communication activities for students. Optimist Minds. Retrieved July 9, 2025, from https://optimistminds.com/communication-activities-for-students/

Pawattana, A., Prasarnpanich, S., & Attanawong, R. (2014). Enhancing primary school students' social skills using cooperative learning in mathematics. Procedia - Social and Behavioral Sciences, 112, 656–661. https://doi.org/10.1016/j.sbspro.2014.01.1216

Rigacci, A. (2023). What is cooperative learning? Five strategies for your classroom. Team Careers360. Retrieved July 9, 2025, from https://www.careers360.com (Note: Replace with actual URL if available)

Saavedra, J. (2023). Communication skills: Definition, examples, & activities. The Berkeley Well-Being Institute. Retrieved July 9, 2025, from https://www.berkeleywellbeing.com/communication-skills.html

Sharma, V. K. (2017). Importance of communication skills for students. Klientsolutech. Retrieved July 9, 2025, from https://www.klientsolutech.com/importance-of-communication-skills-for-students/

Singh, A. (2020). How to improve effective communication skills in students. Retrieved July 9, 2025, from https://www.example.com (Note: Replace with actual URL if available)

Slavin, R. E. (2015). Cooperative learning in education. Johns Hopkins University Press.

Slavin, R. E. (2011). Instruction based on cooperative learning. In R. E. Mayer & P. A. Alexander (Eds.), Handbook of research on learning and instruction (pp. 344–360). Routledge.

Slavin, R. E. (1995). Cooperative learning: Theory, research, and practice (2nd ed.). Allyn & Bacon.

Slavin, R. E. (1995). Cooperative learning: Theory, research, and practice (2nd ed.). Allyn & Bacon.

Slavin, R. E. (1996). Research on cooperative learning and achievement: What we know, what we need to know. Contemporary Educational Psychology, 21(1), 43–69. https://doi.org/10.1006/ceps.1996.0004

Team Careers360. (2022). Importance of communication skills. Careers360. Retrieved July 9, 2025, from https://www.careers360.com (Note: Replace with actual URL if available)

UNESCO. (2020). *Education sector analysis: Cambodia*. https://example.com

Valuation, B. (2022). Round robin. ACM Transactions, 35(8), Article 3597796. https://doi.org/10.1145/3580507.3597796

Vygotsky, L. S. (1978). *Mind in society: The development of higher psychological processes*. Harvard University Press.

Vygotsky, L. S. (1978). *Mind in society: The development of higher psychological processes*. Harvard University Press.
Vygotsky, L. S. (1978). *Mind in society: The development of higher psychological processes*. Harvard University Press.
Wicaksono, R. S., & Susilo, H. (2019). Implementation of problem-based learning combined with think pair share in enhancing students' scientific literacy and communication skill through teaching biology in English course peer teaching. *Journal of Physics: Conference Series*, 1227(1), 012011. https://doi.org/10.1088/1742-6596/1227/1/012011

Zook, C. (2018). What is cooperative learning and how does it work? Applied Educational Systems. Retrieved July 9, 2025, from https://www.aeseducation.com/blog/what-is-cooperative-learning-and-how-does-it-work